# សេចក្តីសង្ខេប
# មតិយោបល់ របស់អង្គការសង្គមស៊ីវិល
# សម្រាប់ច្បាប់ថវិកាឆ្នាំ២០២៦ និងឆ្នាំបន្តបន្ទាប់

ក្រុមការងារថវិការបស់អង្គការសង្គមស៊ីវិល (CSO BWG) ដែលជាសម្ព័ន្ធមួយនៃអង្គការសង្គមស៊ីវិល ដែលផ្តោតលើការលើកកម្ពស់ តម្លាភាព គណនេយ្យភាព និងការត្រួតពិនិត្យថវិកា បានរៀបចំឯកសារគោលជំហរមួយ ក្នុងការផ្តល់មតិយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦ ដែលត្រូវបានគេស្គាល់ជាទូទៅថាជាច្បាប់ថវិកាជាតិ។

មតិយោបល់របស់ក្រុមការងារថវិការបស់អង្គការសង្គមស៊ីវិល ផ្តោតលើ ការបែងចែកថវិកាចំពោះវិស័យសំខាន់ៗដូចជា៖ វិស័យអប់រំ ការលើកកម្ពស់សមភាពយេនឌ័រនិងសមធម៌សង្គម ការអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចគាំពារសង្គមនិងសុខភាពសាធារណៈ ការវិភាជថវិកានិងរដ្ឋបាលថ្នាក់ក្រោមជាតិនិងការគ្រប់គ្រងចំណូល ចំណាយបំណុលសាធារណៈ តាមរយៈប្រសិទ្ធភាពពន្ធដារនិងការប្រមូលចំណូល ការប្រឆាំងអំពើពុករលួយ និងការគ្រប់គ្រងបំណុលសាធារណៈជាដើម។

**ខាងក្រោមនេះគឺជាសម្រង់មតិយោបល់របស់អង្គការសង្គមស៊ីវិល៖**

**១. វិស័យអប់រំ៖** រាជរដ្ឋាភិបាលគួរតែរក្សាការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការបែងចែកយ៉ាងហោចណាស់ ២០% នៃការចំណាយជាតិសម្រាប់ការអប់រំ។ អាទិភាពត្រូវតែផ្តោតលើការបង្កើនគុណភាពអប់រំ និងបន្ថែមការគាំទ្រសាលារៀនជនបទ ដើម្បីឱ្យក្លាយទៅជា "សាលារៀនគំរូ"។ ការបែងចែកថវិកាសម្រាប់ជួសជុលសាលារៀន ហេដ្ឋារចនាសម្ព័ន្ធក្នុងសាលារួមមាន៖ ទឹកស្អាតនិងអនាម័យ ផ្តល់សៀវភៅ និងសម្ភារៈសិក្សាជាដើម។ ការធ្វើឱ្យប្រសើរឡើងនូវបច្ចេក

វិទ្យា និងការកសាងសមត្ថភាពគ្រូបង្រៀន និងពង្រឹងភាពជាដៃគូជាមួយសង្គមស៊ីវិល និងសហគមន៍គឺមានសារៈសំខាន់សម្រាប់ការកែលម្អលទ្ធផលនៃការអប់រំផងដែរ។

**២. ថវិកាឆ្លើយតបទៅនឹងយេនឌ័រ និងសមធម៌សង្គម៖** យើងសូមអបអរសាទរចំពោះការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបន្តការគាំទ្រដល់ការលើកកម្ពស់សមភាពយេនឌ័រ។ ការគាំទ្រដល់ការអនុវត្ត គោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ២០២៤–២០៣៤ ដើម្បីជម្រុញការចូលរួមរបស់ស្ត្រីក្នុងគ្រប់វិស័យ និងធានាសិទ្ធិយេនឌ័រដោយស្មើភាព ផែនការយុទ្ធសាស្ត្រនារីរតនៈទី៦ (២០២៤–២០២៨) ដើម្បីលើកសមត្ថភាពស្ត្រី និងក្មេងស្រីក្នុងការអភិវឌ្ឍជីវភាព និងភាពជាអ្នកដឹកនាំ ជម្រុញការចូលរួមរបស់ស្ត្រីក្នុងវិស័យសេដ្ឋកិច្ច និងនយោបាយ ដោយផ្តល់ឱកាសការងារ ការអប់រំ និងការបណ្តុះបណ្តាលជំនាញ គួរចាត់ជាអាទិភាព រួមជាមួយនិងការបង្កើតប្រព័ន្ធថវិកាឆ្លើយតបនឹងយេនឌ័រ និងប្រព័ន្ធតាមដាន/វាយតម្លៃ ដើម្បីធានាថាវិធានការទាំងអស់មានប្រសិទ្ធភាព និងសមភាពក្នុងការអនុវត្ត។

**៣. ការគាំពារសង្គមនិងសុខភាពសាធារណៈ៖** រាជរដ្ឋាភិបាលគប្បីពង្រីកវិសាលភាព និងសមធម៌នៃគោលនយោបាយកិច្ចគាំពារសង្គម ដើម្បីគ្របដណ្តប់ទៅដល់ក្រុមងាយរងគ្រោះ ដូចជាកម្មករនិយោជិតនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ មនុស្សចាស់ ជនមានពិការភាព និងសហគមន៍ជនជាតិដើម។ គោលនយោបាយទាំងនេះគប្បីចាត់អាទិភាពលើសន្តិសុខប្រាក់ចំណូល សម្រាប់យុវជន ពលករចំណាកស្រុក និងជនអត់ការងារធ្វើ។ បន្ថែមលើនេះ រាជរដ្ឋាភិបាលគប្បីពង្រីកការគ្របដណ្តប់នៃកិច្ចគាំពារសង្គមទៅដល់សហគ្រាសមីក្រូ និងមធ្យម (MSMEs) និងកសិករខ្នាតតូច។

**ការវិនិយោគប្រកបដោយចីរភាពក្នុងសុខភាពសាធារណៈមានសារៈសំខាន់ណាស់ រួមមាន៖** ការពង្រឹងគុណភាព និងសេវា តាមមណ្ឌលសុខភាពសារធារណៈ ជាមួយនឹងការបែងចែកធនធានចាំបាច់ ដូចជា ការផ្តល់សេវាទឹកស្អាត និងមានអនាម័យ នឹងដោះស្រាយវិសមភាពសុខភាពប្រជាជននៅតាមជនបទ និងការបន្សាំខ្លួនទៅនឹងការបម្រែបម្រួលអាកាសធាតុ។ ការត្រួតពិនិត្យសុខភាពបង្ការសម្រាប់មនុស្សពេញវ័យដែលមានអាយុពី 35-50 ឆ្នាំ និងសុខភាពយុវជនគួរតែត្រូវបានពង្រីកផងដែរ។

**៤. ការវិភាជថវិកា និងរដ្ឋបាលថ្នាក់ក្រោមជាតិ៖** យ៉ាងហោចណាស់ ៣០% ការចំណាយនៃថវិកាជាតិគួរតែត្រូវបានបែងចែកទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់អភិបាលកិច្ចមូលដ្ឋាន និងការផ្តល់សេវា។ ការពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងថវិកា ការត្រួតពិនិត្យ និងការធ្វើសវនកម្មនៅថ្នាក់មូលដ្ឋានគឺមានសារៈសំខាន់ ជាពិសេសការចូលរួមពីសាធារណជនក្នុងដំណើរការរៀបចំថវិកាគួរត្រូវបានលើកទឹកចិត្ត ដើម្បីបង្កើនតម្លាភាព និងការទទួលខុសត្រូវ។

**៥. ការគាំទ្រដល់សកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច៖** រាជរដ្ឋាភិបាលគប្បីបង្កើនការវិនិយោគដល់ការពង្រឹងសម្ថភាព និងការលើកទឹកចិត្តដល់**សហគ្រាសធុនតូច និងមធ្យម (SMEs)**ដើម្បីជួយពង្រីកសក្តានុពល បង្កើនភាពរឹងមាំ និងភាព

ប្រកួតប្រជែងរបស់ SMEs ដែលជាផ្នែកសំខាន់នៃសេដ្ឋកិច្ចកម្ពុជា ក៏ដូចជាផ្តល់ឱកាសការងារដល់យុវជន និងជនចំណាកស្រុក។ វិធានការដើម្បីពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់សហគ្រាសធុនតូច និងមធ្យម អាចធ្វើបានតាមរយៈការផ្តល់ជំនួយហិរញ្ញវត្ថុតាមរយៈកម្មវិធីធានាឥណទានដើម្បីពង្រីកសមត្ថភាពផលិត កែច្នៃ និងការបង្កើតតម្លៃបន្ថែមនៃផលិតផលកសិកម្ម ការបញ្ចុះពន្ធសម្រាប់អាជីវកម្មដែលមានការចុះបញ្ជីត្រឹមត្រូវនិងអាជីវកម្មដែលមានទំនួលខុសត្រូវចំពោះសង្គមនិងបរិស្ថាន ការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងអាជីវកម្ម និងបច្ចេកវិទ្យាឌីជីថល ការផ្តល់សេវាអភិវឌ្ឍន៍អាជីវកម្មដូចជា ការប្រឹក្សាអាជីវកម្ម និងការចូលរួមពិព័រណ៌អាជីវកម្ម ការជួយ SMEs ចូលរួមក្នុងទីផ្សារអន្តរជាតិដោយផ្តល់ព័ត៌មានអំពីស្តង់ដារអន្តរជាតិ និងការចូលដំណើរការបច្ចេកវិទ្យាថ្មីៗ ព្រមទាំងការបង្កើតបណ្តាញសហការណ៍ជាមួយស្ថាប័នឯកជន និងអន្តរជាតិ។

**៦. ប្រសិទ្ធភាពពន្ធដារ និងការប្រមូលចំណូល៖** រាជរដ្ឋាភិបាលគប្បីបង្កើនកិច្ចខំប្រឹងប្រែងដើម្បីធានានូវ យុត្តិធម៌ តម្លាភាព និងមានប្រសិទ្ធភាពនៃការប្រមូលចំណូល ដើម្បីជៀសវាងការបាត់បង់សក្តានុពលចំណូលថវិការដ្ឋ។ ពន្ធលើភេសជ្ជៈមានជាតិស្ករ និងផលិតផលដែលបង្កគ្រោះថ្នាក់ដល់សុខភាពរួមមាន៖ គ្រឿងស្រវឹង និងថ្នាំជក់គួរតែកើនឡើង និងបន្ធូបន្ថយពន្ធលើទំនិញចាំបាច់ ដូចជាប្រេងឥន្ធនៈដែលបម្រើសម្រាប់ការដឹកជញ្ជូននិងកសិកម្ម។ ការធ្វើទំនើបកម្មប្រព័ន្ធពន្ធលើអចលនទ្រព្យ និងការបង្កើនតម្លាភាពលើការលើកទឹកចិត្តពន្ធត្រូវបានណែនាំ។

**៧. ការប្រឆាំងអំពើពុករលួយ៖** រាជរដ្ឋាភិបាលគប្បីអនុវត្តគោលនយោបាយដែលមិនអត់ឱនចំពោះអំពើពុករលួយ គឺចាំបាច់នៅក្នុងការគ្រប់គ្រងថវិកាសាធារណៈ។ តម្លាភាពដំណើរការលទ្ធកម្មសាធារណៈ សវនកម្មឯករាជ្យ និងការបង្ហាញជាសាធារណៈនូវកិច្ចសន្យា កិច្ចព្រមព្រៀងហិរញ្ញវត្ថុ និងការវាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងសាធារណៈ គឺចាំបាច់ដើម្បីធានាឱ្យមានគណនេយ្យភាព និងការចូលរួមជាសាធារណៈ។ ពង្រឹងការិយាល័យថវិកាសភាស្វយ័ត ដើម្បីបង្កើនប្រសិទ្ធភាព នឹងធ្វើអោយប្រសើរឡើងនូវការត្រួតពិនិត្យថវិកា ដោយយុត្តិធម៌ និងតម្លាភាពតាមរយៈការធ្វើសវនកម្មឯករាជ្យ វិធានការប្រឆាំងអំពើពុករលួយដោយប្រើប្រាស់បច្ចេកវិទ្យា និងការត្រួតពិនិត្យរបស់សភាផងដែរ ។

**៨. ការគ្រប់គ្រងបំណុលសាធារណៈ៖** រាជរដ្ឋាភិបាលគួរមានការប្រុងប្រយ័ត្នខ្ពស់ចំពោះកម្ចីណាដែលបានផ្តល់ហានិភ័យដល់ប្រទេសជាតិទាំងមូល និងមានផលប៉ះពាល់ដល់សេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋរបស់ខ្លួន និងប៉ាន់ប្រមាណសមត្ថភាពកម្រិតចំណូល និងចំណាយជាតិប្រចាំឆ្នាំ និងការសងត្រឡប់ទៅឲ្យគេវិញ។ ការខ្ចីប្រាក់គួរតែផ្តោតលើគម្រោងដែលផ្តល់អត្ថប្រយោជន៍ដល់សង្គម និងសេដ្ឋកិច្ចច្បាស់លាស់ ដែលជួយសម្រាលដល់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ជាពិសេសសម្រាប់ក្រុមងាយរងគ្រោះ។